# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទថា អ្នកខ្លះនិយាយថា សាសនាណាក៏ដូចសាសនាណាដែរ តែងតែប្រៀនប្រដៅឲ្យមនុស្សធ្វើល្អ តើពាក្យនេះត្រឹមត្រូវទៅតាមការពិតឬទេ ?

web site: hoksavann.org

ថ្ងៃទី៥ កក្កដា ២០០៦

គោលបំណងរបស់អ្នកបង្កើតឲ្យមានសាសនា តែបំណងឲ្យបរិស័របស់ខ្លួនបានសុខ ប៉ុន្តែមធ្យោបាយទៅរកបំណងនោះ ពិតជាមានលក្ខណ:ផ្សេងគ្នា ។ បើនិយាយពីភាពល្អមានបីថ្នាក់គឺ ÷ ទី១- ល្អធម្មតា, ២- ល្អដោយប្រៀបធៀបគ្នា, ៣- ល្អបណ្តាច់គឺល្អដាច់គេ ។ ចំពោះព្រះពុទ្ធសាសនា ធម៌វិន័យរបស់ព្រះអង្គដែលប្រៀនប្រដៅមនុស្សសត្វ ជាធម៌បរិសុទ្ធជាធម៌មិនបៀតបៀន ។ លក្ខណ:វិនិច្ឆ័យធម៌វិន័យ ៨ប្រការតទៅនេះ ចាត់ជាធម៌វិន័យរបស់ព្រះពុទ្ធគឺ ÷ ១- វិរាគាយ: ប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក, ២- វិសំយោគាយ: ប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ, ៣- អបចយាយ: ប្រព្រឹត្តទៅដើម្បីមិនសន្សំកិលេស, ៤- អប្បិច្ឆតាយ: ប្រព្រឹត្តទៅដើម្បីប្រាថ្នាតិច, ៥- សន្តុដ្ឋិយា ប្រព្រឹត្តទៅដើម្បីសេចក្តីត្រេកអរចំពោះវត្ថុតាមមានតាមបាន, ៦- បវិវេកាយ: ប្រព្រឹត្តទៅដើម្បីស្ងាត់ចាកពួកគណ:, ៧- វីនិយារម្ភាយ: ប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម, ៨- សុភរតាយ: ប្រព្រឹត្តទៅដើម្បីការចិញ្ចឹមងាយ ។ ធម៌ទាំង៨នេះ គប្បីដឹងថា ជាធម៌វិន័យរបស់ព្រះពុទ្ធ ។ ធម៌ផ្ទុយពីនេះ គប្បីដឹងថា មិនមែនជាធម៌វិន័យពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធឡើយ ។ លក្ខណ:វិនិច្ឆ័យជាធម៌វិន័យរបស់ព្រះពុទ្ធ ដែលប្រៀនប្រដៅមនុស្សសត្វ តើដូចពាក្យប្រៀនប្រដៅរបស់សាសនាណាមួយឬទេ ? ពិតជាពុំដូចឡើយ ។

ព្រះពុទ្ធមិនបង្ខំឲ្យគេជឿ គឺព្រះអង្គគោរពសិទ្ធិមនុស្សខាងជំនឿ ដោយព្រះអង្គបានប្រកាសជាមុនថា មុននឹងជឿធម៌វិន័យដែលតថាគតសំដែង អ្នកមានសិទ្ធិពេញទីក្នុងការពិចារណាឲ្យបានល្អិតល្អន់ និងធ្វើការពិសោធន៍ឲ្យយល់ច្បាស់ជាមុនសិន។

តើលក្ខណៈព្រះពុទ្ធបែបនេះ មានសាសនាណាមានលក្ខណៈដូចនេះឬទេ ។ ផ្ទុយទៅវិញ គេបានឮថា មានសាសនាខ្លះយកអំណោយទៅចែកឲ្យប្រជាជននៃប្រទេសក្រីក្រ ហើយបង្ខំឲ្យគេជឿនូវសាសនារបស់ខ្លួន រហូតបង្ខំកូនក្មេង ដែលជាវ័យមិនទាន់ចេះពិចារណាឲ្យជឿទៀតផង ។ ចំពោះអំណោយទានតាមលក្ខណៈព្រះពុទ្ធសាសនា ចំពោះជនណាម្នាក់ គឺធ្វើឡើងដើម្បីលះមច្ឆរិយៈសេចក្តីកំណាញ់ ដោយបូជាគុណក្តី ដោយសង្គហធម៌ក្តី ដោយចិត្តបរិសុទ្ធ គ្មានចង់បានអ្វីមកវិញឡើយ ។ នេះបញ្ជាក់ថា មានជនជាតិនៃប្រទេសអ្នកមាន កំពុងព្យាយាមបំបាត់វប្បធម៌នៃជនជាតិនៃប្រទេសអ្នកក្រ ។ មានសាសនាខ្លះបង្រៀនមិនឲ្យមនុស្សបៀតបៀនគ្នាដែរ ។ ប៉ុន្តែមានលក្ខណៈចង្អៀតដោយមានព្រំដែន ដូចជាការរក្សាសីលរបស់ពួកនិគ្រន្ថហៅថានិគន្ថឧបោសថ ដែលព្រះពុទ្ធហាមមិនឲ្យរក្សាសីលតាមពួកនោះ ដូចវៀរចាកសម្លាប់សត្វទិសខាងកើតចម្ងាយមួយយោជន៍ ឯសត្វទិសដទៃសម្លាប់បាន ។ សាសនាខ្លះមិនឲ្យសម្លាប់មនុស្ស តែសត្វអាចសម្លាប់បាន ព្រោះសត្វនៃសាសនាគេបង្កើតឡើងសំរាប់ជាអាហាររបស់មនុស្ស ។ មានសាសនាខ្លះបើកឲ្យសម្លាប់មនុស្ស បើមនុស្សនោះជាសត្រូវរបស់សាសនាខ្លួន ។ ចំពោះព្រះពុទ្ធសាសនាវិញ ហាមមិនឲ្យសម្លាប់ជីវិតមនុស្សនិងសព្វសត្វទាំងអស់ ។ បានសេចក្តីថា ឲ្យតែគេមានជីវិតសញ្ញាចង់រស់នៅមិនចង់ស្លាប់ មិនត្រូវសម្លាប់ឡើយត្រូវតែគោរពជីវិតមនុស្សសត្វទាំងអស់ សូម្បីតែសត្រូវរបស់ខ្លួនក៏ដោយ ។ មួយទៀតគ្មានសត្វណាកើតមក សំរាប់មនុស្សស៊ីឡើយ ប៉ុន្តែសត្វត្រូវតែចាញ់ ព្រោះពុំអាចទាមទារសិទ្ធិរបស់ខ្លួនបាន ។ ចំណែកព្រះពុទ្ធសាសនាឲ្យគោរពរហូតដល់សិទ្ធិសត្វ ដូចមានចែងក្នុងសិក្ខាបទទី១នៃសីល៥ ។ គឺជាសីលធម៌គ្មានកំណត់ព្រំដែន ជាសីលធម៌ដ៏ខ្ពង់ខ្ពស់ គ្មានរបបលទ្ធិសាសនាណាប្រដូចបានឡើយ ។ ដូច្នេះហើយបានជានៅឆ្នាំ២០០៦នេះ ប្រទេសកាន់ព្រះពុទ្ធសាសនាក្នុងលោក បានប្រគល់ឲ្យប្រទេសកម្ពុជារៀបចំបុណ្យពិសាខបូជា នៅទីស្នាក់ការអង្គការសហប្រជាជាតិ ដែលបុណ្យនេះបានត្រូវអង្គការពិភពលោកនេះអនុម័តឲ្យធ្វើ នៅទីស្នាក់ការរបស់ខ្លួនតាំងពីថ្ងៃទី១៣ធ្នូ១៩៩៩ ដែលចាត់ទុកជាបុណ្យអន្តរជាតិ ព្រោះគេមើលឃើញថា ព្រះពុទ្ធសាសនាជាមូលដ្ឋាននៃការគោរពសិទ្ធិមនុស្ស ត្រង់ធម៌អហឹង្សា ការមិនបៀតបៀន សូម្បីសត្វតិរច្ឆានព្រះអង្គមិនឲ្យបៀតបៀនផង ។ ក្នុងធម្មគុណពោលថា ស្វាក្ខាតោ ប្រែថាធម៌គឺព្រះដ៏មានព្រះភាគសំដែងល្អហើយ ត្រឹមត្រូវហើយ ជានិយ្យានិកធម៌ ជាធម៌ដឹកនាំសត្វឲ្យចេញចាកទុក្ខ មានជាតិទុក្ខជាដើម ជាបច្ចត្តំ វេទិតព្វោ ជាធម៌ គឺព្រះអរិយបុគ្គលគប្បីដឹងពិតឃើញពិតក្នុងចិត្តនៃខ្លួន ។

ដូចបានពោលមកហើយបញ្ជាក់ថា ពាក្យប្រៀនប្រដៅរបស់សាសនាដទៃមានភាពល្អខ្លះ ប៉ុន្តែជាល្អធម្មតារបស់មនុស្សបុថុជ្ជន ហើយល្អមានព្រំដែន ល្អមានលក្ខខ័ណ្ឌល្អ មានបំណងល្អ ពុំមានភាពបរិសុទ្ធ ។ ចំណែកពាក្យប្រៀនប្រដៅរបស់ព្រះ

ពុទ្ធជាម្ចាស់វិញ មានភាពសុក្រឹត មានភាពបរិសុទ្ធ អាចញុំាងអ្នកប្រតិបត្តិតាម ឲ្យចេញចាកទុក្ខ ជាធម៌របស់ព្រះអរិយបុគ្គល នាំសត្វឲ្យរំលត់ទុក្ខ ពោលគឺព្រះនិព្វាន ឈប់វិលកើតវិលស្លាប់ ។ ឯសាសនាដទៃនិយាយថា នាំសត្វទៅស្ថានព្រហ្មនិងស្ថានសួគ៌ ដែលស្ថានទាំងនោះ ព្រះពុទ្ធសំដែងថា ស្ថិតនៅក្នុងភពនៅវិលកើតវិលស្លាប់ ទទួលទុក្ខវេទនាគ្មានទីបំផុតឡើយ ។៚

❏ ❏

❏